# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

គណៈកម្មាធិការលទ្ធកម្ម

លេខ:..០៥.../២០ គ.ល

**សេចក្តីជូនដំណឹង**

**ស្តីពី**

**ការអញ្ជើញចូលរួមដេញថ្លៃការផ្គត់ផ្គង់សម្ភារបរិក្ខារពិសោធន៍ប្រើប្រាស់ក្នុងឆ្នាំ២០របស់អគ្គនាយកដ្ឋានកសិកម្ម**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាស ឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ឱ្យបានជ្រាបថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកផ្គត់ផ្គង់សម្ភារបរិក្ខារពិសោធន៍ សម្រាប់ប្រើប្រាស់ក្នុងឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានកសិកម្ម។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី..០២....ខែ.កក្កដា.ឆ្នាំ២០២០ តទៅរៀងរាល់ម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០១២ ៩១៦ ៩២៦ , ០១៦ ៦១ ៦៦ ៨២)។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ យ៉ាងយូរបំផុតត្រឹមថ្ងៃទី..០៤....ខែ..សីហា..ឆ្នាំ២០២០ វេលាម៉ោង.០៩:០០ព្រឹក។

ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមអាសយដ្ឋានខាងលើ វេលាម៉ោង.០៩:០០ព្រឹក ថ្ងៃទី..០៤....ខែ..សីហា.ឆ្នាំ២០២០ ។

ក្រុមហ៊ុន/សហគ្រាស ដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាស ដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

ថ្ងៃ ព្រហ..១១កើត ខែ.អាសាឍ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ....០១.... ខែ កក្កដា. ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

**វេង សាខុន**

**ចម្លងជូន៖**

- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ កាលប្បវត្តិ